UNITED NATIONS
CAMBODIA

# ការធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩
## ឯកសារព័ត៌មានទី ៥
## ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០២១

ការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ និងវិធានការឆ្លើយតប ដើម្បីបង្អង់ល្បឿននៃការឆ្លងរាលដាលវីរុសនេះ នាំឲ្យប្រទេសជាច្រើននៅក្នុងពិភពលោក ជួបប្រទះនឹងឱនភាពសេដ្ឋកិច្ច ដែលនាំឲ្យបញ្ហាអសន្តិសុខស្បៀង និងបញ្ហាអាហារូបត្ថម្ភមានការកើនឡើង។

មុនពេលការរាតត្បាតជាសកលនេះកើតឡើង ប្រទេសកម្ពុជាសម្រេចបាននូវវឌ្ឍនភាពគួរឲ្យកត់សម្គាល់ ក្នុងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ យ៉ាងណាក្តី ប្រេវ៉ាឡង់នៃបញ្ហាកង្វះអាហារូបត្ថម្ភ នៅបន្តមានកម្រិត ១៤% ហើយបញ្ហាអាហារូបត្ថម្ភនៅតែបន្តមាន ក្នុងគ្រប់ទម្រង់ទាំងអស់។ ក្នុងចំណោមកុមារអាយុក្រោម ៥ ឆ្នាំ បីនាក់ មានមួយនាក់ ដែលជួបប្រទះនឹងបញ្ហាអាហារូបត្ថម្ភរ៉ាំរ៉ៃ ហើយក្នុងចំណោមកុមារ ១០ នាក់ មានមួយនាក់ ដែលជួបប្រទះនឹងបញ្ហាអាហារូបត្ថម្ភស្រួចស្រាវ។ កង្វះមីក្រូសារជាតិចិញ្ចឹមក៏កើតមានជាទូទៅផងដែរ ហើយបញ្ហាធាត់ជ្រុលក៏កំពុងខ្ពុំមានការកើនឡើង។

ប្រព័ន្ធអង្គការសហប្រជាជាតិនៃកម្ពុជាមានការបារម្ភអំពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើសន្តិសុខស្បៀង និងស្ថានភាពអាហារូបត្ថម្ភរបស់ក្រុមងាយរងគ្រោះ ដូចជា ជនក្រីក្រ ស្ត្រី និងកុមារ និងអ្នកដែលកំពុងមានបញ្ហាសុខភាពប្រចាំកាយ មនុស្សចាស់ និងជនដែលគ្មានទីជម្រក។ បញ្ហាអសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស ហើយការទទួលបានស្បៀង និងអាហារូបត្ថម្ភ គឺជាសិទ្ធិមនុស្សជាមូលដ្ឋានរបស់មនុស្សគ្រប់រូប។ ជាការពិត ការបាត់បង់ប្រាក់ចំណូល និងមុខរបរចិញ្ចឹមជីវិត ធ្វើឲ្យលទ្ធភាពទទួលបានស្បៀងអាហារមានការថយចុះ និងបង្កើនការលំបាកដល់មនុស្សជាច្រើននាក់ ដែលកំពុងជួបប្រទះនឹងការលំបាករួចទៅហើយ ក្នុងការទទួលបាននូវរបបអាហារគ្រប់គ្រាន់ ដើម្បីទ្រទ្រង់សុខភាពក្នុងតម្លៃសមរម្យ ក៏ដូចជាសេវានានា។ ការសិក្សាមួយរបស់អង្គការសហប្រជាជាតិដែលបានចេញផ្សាយកាលពីខែ មេសា ឆ្នាំ ២០២១ បង្ហាញថា នៅក្នុងរយៈពេល ៦ ខែចុងក្រោយនេះ ប្រជាពលរដ្ឋកាន់តែប្រើប្រាស់យុទ្ធសាស្ត្រទប់ទល់មួយចំនួនពាក់ព័ន្ធនឹងការទទួលបានស្បៀង ដូចជា កាត់បន្ថយបរិមាណអាហារហូបចុក ការពឹងលើជម្រើសអាហារដ៏មានតម្លៃថោក និងការខ្ចីបុល ជាដើម។ ការសិក្សានេះបានរំលេចឲ្យឃើញថា គ្រួសារដែលត្រូវបានកំណត់អត្តសញ្ញាណថាជាគ្រួសារក្រីក្រ គ្រួសារដែលមានសមាជិកតិច (១-៣ នាក់) និងគ្រួសារដែលមានសមាជិកមានពិការភាព ទំនងជាមានស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងកម្រិតទាប។ នៅចុងឆ្នាំ ២០២០ ស្ត្រីកម្ពុជាមានអាយុពី ១៥ ដល់ ៤៩ ឆ្នាំ ត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ ដែលបានទទួលរបបអាហារចម្រុះគ្រប់គ្រាន់ (ថយចុះពី ៧០% កាលពីដើមឆ្នាំនេះ)។ អ្នកជំនាញផ្នែកសុខភាពសាធារណៈបានព្យាករថា បញ្ហាអាហារូបត្ថម្ភស្រួចស្រាវនៅក្នុងប្រទេសចំណូលទាប និងចំណូលមធ្យមចំណូលមធ្យមកម្រិតទាប នឹងកើនឡើង ១៤% ដោយសារតែវិបត្តិកូវីដ-១៩ នេះបើតាមអត្ថបទនៅក្នុងទស្សនាវដ្តី Lancet (ខែ កក្កដា ឆ្នាំ ២០២០)។

វិនិយោគលើការការពារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានសារៈសំខាន់ និងជារឿងចាំបាច់ក្នុងការឆ្លើយតបចំពោះវិបត្តិកូវីដ-១៩ ព្រោះថា៖

- របបអាហារដែលមានគុណភាព និងជួយទ្រទ្រង់សុខភាពសម្រាប់ទាំងអស់គ្នា គឺជាគន្លឹះដើម្បីបង្កើនភាពស៊ាំរបស់រាងកាយ និងបង្ការជំងឺមិនឆ្លងនានា ដែលជាកត្តាហានិភ័យនាំឱ្យអត្រាឈឺ និងស្លាប់ដោយសារជំងឺកូវីដ-១៩ កើនឡើងខ្ពស់។
- បញ្ហាអាហារូបត្ថម្ភនៅវ័យកុមារ និងក្នុងអំឡុងពេលមានផ្ទៃពោះ បង្កផលលំបាកអវិជ្ជមានធ្ងន់ធ្ងរជំនាន់ ដល់ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ និងបង្កផលប៉ះពាល់ពេញមួយជីវិតមកលើការអប់រំ ក៏ដូចជាការប្រឈមនឹងជំងឺរ៉ាំរ៉ៃនានា។
- បញ្ហាអសន្តិសុខស្បៀង និងអាហារូបត្ថម្ភ បង្កផលវិបាកយូរអង្វែងដល់មូលធនមនុស្ស ផលិតភាពសេដ្ឋកិច្ច និងការអភិវឌ្ឍជាតិជារួម។ នៅក្នុងឆ្នាំ ២០១៦ មានការប៉ាន់ប្រមាណថា បញ្ហាហិរញ្ញវត្ថុអាហារូបត្ថម្ភធ្វើឲ្យសេដ្ឋកិច្ចខាតបង់ទឹកប្រាក់ចំនួន ២៦៦ លានដុល្លារ ក្នុងមួយឆ្នាំ (១,៧% នៃផ.ស.ស)។

អង្គការសហប្រជាជាតិជំរុញឲ្យមានការប្រើប្រាស់អភិក្រមដែលមានលក្ខណៈជាប្រព័ន្ធចម្រុះវិស័យ មានភាពប្រទាក់ក្រឡាគ្នា និងឈរលើគោលការណ៍សិទ្ធិ ដើម្បីឆ្លើយតបចំពោះបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ តាមរយៈគំនិតផ្តួចផ្តើមនានា ដូចជា គំនិតផ្តួចផ្តើមអាហារូបត្ថម្ភរបស់អង្គការសហប្រជាជាតិ (UN Nutrition) ជាដើម ប្រព័ន្ធអង្គការសហប្រជាជាតិទាំងមូលប្រើប្រាស់សំឡេងតែមួយ ដើម្បីជំរុញឲ្យមានការផ្តល់អាទិភាព និងការប្តេជ្ញាចិត្តលើកកម្ពស់សន្តិសុខស្បៀងអាហារូបត្ថម្ភ ក៏ដូចជាការទទួលបានស្បៀងសម្រាប់ទាំងអស់គ្នា ហើយក្នុងពេលជាមួយគ្នា សហការជាមួយដៃគូនានា ដើម្បីសម្រេចគោលដៅ ដែលត្រូវបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងផែនទីបង្ហាញផ្លូវការស្តីពីការបង្ការ និងការព្យាបាលបញ្ហាស្គមស្គាំង ដែលទើបតែប្រកាសដាក់ឱ្យអនុវត្តកាលពីពេលថ្មីៗនេះ។

អង្គការសហប្រជាជាតិក៏គាំទ្រដល់អន្តរាគមន៍ជាច្រើន នៅក្នុងប្រព័ន្ធស្បៀង អប់រំ សុខាភិបាល គាំពារសង្គម ព្រមទាំងទឹកស្អាត និងអនាម័យផងដែរ។ ជាមួយនឹងកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងរបស់អង្គការសហប្រជាជាតិ ដែលនឹងរៀបចំនៅក្នុងខែ កក្កដា ឆ្នាំ ២០២១ នាពេលខាងមុខនេះ អង្គការសហប្រជាជាតិកំពុងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំកិច្ចសន្ទនាដែលមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ បង្កើនការយល់ដឹង នឹងកៀរគរការចូលរួមធ្វើសកម្មភាពពីតួអង្គពាក់ព័ន្ធចម្រុះ ដើម្បីកសាងនូវមាគ៌ាដែលនាំឲ្យប្រព័ន្ធស្បៀងកាន់តែមាននិរន្តរភាពយូរអង្វែង។

ពាក់ព័ន្ធនឹងវិបត្តិកូវីដ-១៩ វិញ អង្គការសហប្រជាជាតិកំពុងរួមចំណែកផ្តល់នូវទិន្នន័យប្រកបដោយគុណភាពតាមរយៈការប្រមូលទិន្នន័យបឋមជាទៀងទាត់ពីក្រុមគ្រួសារ ដើម្បីវាស់វែងការវិវឌ្ឍនៃស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក៏ដូចជាប្រសិទ្ធភាពនៃការអនុវត្តវិធានការកាត់បន្ថយហានិភ័យនានា។

កិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយសង្គមនៅក្នុងប្រទេស ជាពិសេស ការបង្កើនប្រាក់ឧបត្ថម្ភ និងការផ្តល់របបអាហារតាមកាលវេលាកំណត់ទៀងទាត់ ជំនួសឲ្យកម្មវិធីផ្តល់អាហារតាមសាលារៀន ដែលអនុវត្តដោយរដ្ឋាភិបាល ចាប់តាំងពីខែមេសា ឆ្នាំ ២០២០ មកបានបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការកាត់បន្ថយការបន្តធ្លាក់ចុះនូវស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ក្រុមទីទ័លក្រជាងគេ។ អង្គការសហប្រជាជាតិបានគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះ ហើយនឹងបន្តចូលរួមសហការ តាមរយៈការស្វែងរកការគាំទ្រ និងការផ្តល់ជំនួយបច្ចេកទេស ដើម្បីជំរុញឲ្យកម្មវិធីផ្តល់ជំនួយសង្គមកាន់តែគិតគូរពីអាហារូបត្ថម្ភ និងកសាងភាពឆ្លើយតបចំពោះវិបត្តិនានា។

ជាការបំពេញបន្ថែមលើគំនិតផ្តួចផ្តើមឆ្លើយតបចំពោះវិបត្តិកូវីដ-១៩ នៅក្នុងប្រទេស អង្គការសហប្រជាជាតិក៏កំពុងផ្តល់កញ្ចប់ស្បៀង និងប្រាក់ឧបត្ថម្ភដោយផ្ទាល់ ដែលពេលខ្លះការឧបត្ថម្ភទាំងនេះ ត្រូវបានផ្តល់រួមគ្នា ជាមួយនឹងការផ្តល់ធនធានផលិតកម្ម ការបណ្តុះបណ្តាលបច្ចេកទេស និងសេវាផ្សព្វផ្សាយដល់ក្រុមងាយរងគ្រោះជាងគេ ដូចជា គ្រួសារ

ក្រីក្រដែលរងផលប៉ះពាល់ដោយសារវិបត្តិផ្សេងៗ កម្មករនិយោជិតក្រៅប្រព័ន្ធ ពលករទេសន្តប្រវេសន៍ដែលវិលត្រឡប់មកស្រុកកំណើតវិញ កសិករខ្នាតតូច កុមារតូច ស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលកំពុងបំបៅកូនដោះ។

ឧទាហរណ៍ អង្គការសហប្រជាជាតិបានបើករបបស្បៀង សម្រាប់យកទៅផ្ទះវិញ ដល់សិស្សចំនួនសិស្សជាង ៨៩ ៥០០ នាក់ មកពីគ្រួសារក្រីក្រ។ ការបែកចែកស្បៀងជុំបន្ទាប់ នឹងធ្វើឡើងនៅក្នុងខែ មិថុនា ឆ្នាំ ២០២១ នេះ។ អង្គការសហប្រជាជាតិ និងដៃគូរបស់ខ្លួន ក៏កំពុងផ្តល់ការឧបត្ថម្ភគាំទ្រដល់ប្រជាពលរដ្ឋប្រមាណ ១ ៥០០ គ្រួសារដែលរងផលប៉ះពាល់ដោយសារវិបត្តិកូវីដ-១៩ នៅក្នុងខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ដើម្បីស្តារជីវភាពរស់នៅរបស់ពួកគេឡើងវិញផងដែរ។

ពាក់ព័ន្ធនឹងវិធានការបិទខ្ទប់ទីក្រុងក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩កាលពីពេលថ្មីៗនេះ ដូចដែលបង្ហាញជូននៅក្នុងឯកសារព័ត៌មានទី ២ ស្តីពីសេវាគាំពារសង្គម ប្រព័ន្ធអង្គការសហប្រជាជាតិនៅកម្ពុជាបានជំរុញឲ្យមានការឆ្លើយតបចំពោះវិបត្តិកូវីដ-១៩ ដោយឈរលើគោលការណ៍សិទ្ធិមនុស្ស និងប្រើប្រាស់អភិក្រម "មិនបង្កគ្រោះថ្នាក់" ដោយផ្តោតការយកចិត្តទុកដាក់៖ (i) លើការការពារសមត្ថភាពរបស់មនុស្សគ្រប់រូប រាប់បញ្ចូលទាំងក្រុមអ្នកងាយរងគ្រោះជាងគេក្នុងការទទួលបានរបបអាហារចម្រុះដែលមានតុល្យភាព និងមានអាហារូបត្ថម្ភ តាមរយៈការផ្តល់ជំនួយជាស្បៀងអាហារ និងការពង្រីកសេវាគាំពារសង្គម, (ii) ចាត់ទុកផលិតកម្មស្បៀង ការផ្សព្វផ្សាយទីផ្សារ និងការចែកចាយស្បៀងថាជាសេវាចាំបាច់សំខាន់ៗ, (iii) លើកកម្ពស់ការប្រាស្រ័យទាក់ទងទ្វេទិស ដើម្បីឆ្លើយតបចំពោះបញ្ហាពាក់ព័ន្ធនឹងការទទួលបានស្បៀងកាន់តែមានប្រសិទ្ធភាព, និង (iv) ដាក់ចេញនូវវិធានការត្រៀមបង្ការ ដើម្បីឲ្យការឆ្លើយតបកាន់តែមានភាពល្អប្រសើរ ក្នុងករណីដែលមានការអនុវត្តវិធានការស្រដៀងគ្នានេះទៀតនាពេលអនាគត។

###

ឯកសារព័ត៌មានស្តីពីការឆ្លើយតបរបស់អង្គការសហប្រជាជាតិនៅកម្ពុជាចំពោះបញ្ហាកូវីដ-១៩ គឺជាឯកសារផ្លូវការដែលផលិតដោយអង្គការសហប្រជាជាតិនៅកម្ពុជា ដើម្បីផ្សព្វផ្សាយជូនអ្នកសារព័ត៌មាន និងដៃគូដទៃទៀត។ ឯកសារទាំងនេះត្រូវបានរៀបចំដោយការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកញ្ញា កែវ ស្រីស្រស់ មន្ត្រីទំនាក់ទំនងនិងស្វែងរកការគាំទ្រនៃការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា តាមរយៈអ៊ីមែល៖ sreysros.keo@un.org។